# វប្បធម៌នៃសម័យកាលកូហ្វុន

កូហ្វុន (Kofun) គឺជាឈ្មោះ នៃសម័យកាលមួយក្នុងប្រវត្តិសាស្ត្រនៃប្រទេសជប៉ុន ដោយនៅក្នុងវេបសាយរបស់ Unesco បានកំណត់សម័យកាលកូហ្វុន គឺចាប់ពីស.វ.ទី៣ រហូតដល់ស.វ.ទី៦នៃគ.ស. ដែលមានផ្នូរចំនួនជាង ១៦០០០០[១] ប៉ុន្តែនៅក្នុងវេបសាយរបស់សារមន្ទីរ Metropolitan បានកំណត់ចាប់ ពីស.វ.ទី២ ដល់ស.វ.ទី ៨នៃគ.ស. ពោលគឺចាប់ពីឆ្នាំ ៣០០ នៃគ.ស. រហូតដល់ឆ្នាំ ៧១០នៃគ.ស.។[២] ចំពោះឈ្មោះកូហ្វុន គឺមានន័យថា ជាភ្នំចាស់នៅក្នុងភាសាជប៉ុន ដោយសំដៅលើផ្នូរដែលជាកន្លែងកប់សពសម្រាប់វណ្ណៈអភិជននៅអំឡុងសម័យកាលនោះ[៣] ដោយនៅចុងស.វ.ទី២ រហូតដល់ស.វ.ទី៥នៃគ.ស. ការកសាងផ្នូរកូហ្វុន គឺមានការកើនឡើងជាខ្លាំងដែលជាការបង្ហាញអំពីការរីកចម្រើននៃការគ្រប់គ្រងក្នុងសម័យកូហ្វុននេះ និងជាសម័យកាលមុនពេលដែលមានឥទ្ធិពលចិនចូលក្នុងប្រទេសជប៉ុន។ នៅចុងស.វ.ទី ៥ អំណាចនយោបាយត្រូវបានគ្រប់គ្រងដោយត្រកូលយ៉ាម៉ាតូ (Yamato) ដែលបានគ្រប់គ្រងលើកោះ ហុនស្ស៊ូ (Honshū) និងពាក់កណ្តាលភាគខាងជើងនៃតំបន់គីយូស្ស៊ូ (Kyūshū) ហើយបន្តបន្ទាប់មកបានបង្កើតអាណាចក្រក្នុងប្រទេសជប៉ុន។[៤]

ស្ថានីយបុរាណវិទ្យា Mozu-Furuichi Kofun Group គឺជាបណ្តុំនៃផ្នូរជាច្រើនក្នុងសម័យកាលកូហ្វុន ដោយមាន៤៩ផ្នូរដែលស្ថិតនៅតំបន់ Mozu និង Furuichi ស្ថិតនៅផ្នែកខាងលើនៅតំបន់ខ្ពង់រាប អូសាកា។ ចំពោះទីតាំងនេះ គឺជាតំបន់មជ្ឈមណ្ឌលនយោបាយ វប្បធម៌ដ៏សំខាន់ នៃប្រជុំកោះជប៉ុននាសម័យបុរាណ (Ancient Japanese archipelago)។[៥] ស្ថានីយ

---

[១] https://whc.unesco.org/en/list/1593

[២] https://www.metmuseum.org/toah/hd/kofu/hd_kofu.htm

[៣] Ibid

[៤] Ibid

[៥] https://www.bunka.go.jp/seisaku/bunkazai/shokai/sekai_isan/ichiran/pdf/r1419077_06.pdf

អត្ថបទដោយ៖ អេង តុលា

បុរាណវិទ្យានេះ ត្រូវបានចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅក្នុងឆ្នាំ២០១៩ ដែលមានផ្ទៃដីសរុប ១៦៦.៦៦ ហិតា (រូបលេខ១-៣)។

ចំពោះទីតាំងនៃសំណង់ផ្នូរកូហ៊ុន នៅក្នុងតំបន់ ម៉ូហ្សូ (Mozu) និងហ្វូរូឈី (Furuichi) គឺបែងចែកមានពីរផ្នែក ដែលមួយស្ថិតនៅក្នុងតំបន់ ម៉ូហ្សូ (Mozu) ដែលបច្ចុប្បន្នជាទីក្រុងសាកៃ (Sakai) និងតំបន់ ហ្វូរូឈី (Furuichi) ដែលមានទីក្រុង ហាប៊ីគីណូ (Habikino) និង ទីក្រុងហ្វីជីដេរ៉ា (Fujiidera)។

នៅក្នុងសម័យកាលកូហ៊ុនដែលកសាងសំណង់ផ្នូរទាំងអស់នោះ បែងចែកជាបីសម័យកាល គឺសម័យដើមនៃកូហ៊ុន ( ពាក់កណ្ដាលស.វ.ទី៣ រហូតដល់ដើមស.វ.ទី ៤នៃ គ.ស.) សម័យកាលពាក់កណ្ដាលនៃកូហ៊ុន (ពាក់កណ្ដាលស.វ.ទី ៤ រហូតដល់ចុងនៃពាក់កណ្ដាលស.វ.ទី៥) និងសម័យកាលចុងកូហ៊ុន( ស.វ.ទី៦)។[៦]

ចំពោះរចនាសម្ព័ន្ធនៃផ្នូរកូហ៊ុន គឺមានសភាពប្លែក និងមានតែមួយ (Unique) ដោយមានផ្ទៃដីធំដែលមានរាងជាការ៉េ ឬ មូល និងមានរាងដូចសោរ ដែលច្រកចូលរាងដូចកន្លែងចាក់សោរ (Key hole) និងមានគូទឹកព័ទ្ធជុំវិញដែលបង្ហាញអំពីបច្ចេកទេស និងគំនិតខ្ពស់ក្នុងការកសាងសំណង់ផ្នូរ។ ផ្នូរដែលស្ថិតនៅក្នុងតំបន់ Mozu និង Furuichi ទាំងអស់គឺមានទំហំពុំដូចគ្នាទេ ប៉ុន្តែគំនិត និងរចនាសម្ព័ន្ធគឺដូចគ្នា។ ដំបូងឡើយផ្នូរទាំងនោះ គឺកសាងជាបន្ទប់សាមញ្ញ និងពុំមានការតុបតែងអ្វីទេ និងមានមឈូសឈើនៅបន្ទប់ខាងក្នុងផ្នូរ[៧] ប៉ុន្តែចាប់ពីស.វ.ទី៦មក បន្ទប់នៅក្នុងផ្នូរ គឺមានការតុបតែងជាគំនូរផ្សេងជាដើម (រូបលេខ៤-៥)។

តាមរយៈនៃការកំណាយនៅតាមបណ្ដាផ្នូរទាំងនោះ អ្នកស្រាវជ្រាវបានរកឃើញនូវវត្ថុសិល្បៈជាច្រើនដែលត្រូវបានបញ្ចុះនៅក្នុងផ្នូរទាំងនោះ ដោយរួមមាន រូបសំណាក់ធ្វើ

---

[៦] https://www.bunka.go.jp/seisaku/bunkazai/shokai/sekai_isan/ichiran/pdf/r1419077_06.pdf

[៧] https://www.metmuseum.org/toah/hd/kofu/hd_kofu.htm

ពីដីដុត ដូចជា រូបសត្វ រូបមនុស្ស អាវគ្រោះ គ្រឿងអាវុធ គ្រឿងអលង្ការធ្វើពីអង្កាំ និងកុលាភាជន៍ជាច្រើនទៀត (រូបលេខ៦-៧)។

សរុបមកកូហ្វុន គឺជាសម័យកាលដែលការកសាងសំណង់ផ្នូរដោយមានទំហំធំនៅក្នុងប្រទេសជប៉ុន និងតាមរយៈសំណង់ទាំងនោះ បានបង្ហាញអំពីទំនៀម ឬ ប្រពៃណីនៃការបញ្ចុះសពរបស់ប្រជាជនជប៉ុនចាប់ពីស.វ.ទី៣ ដល់ទី៦ នៃគ.ស.។




រូបលេខ១៖ ផែនទីទូទៅ នៃតំបន់ Mozu និង Furuichi

ប្រភព៖ https://www.bunka.go.jp

អត្ថបទដោយ៖ អេង តុលា



រូបលេខ២-៣៖រូបថតពីលើ ផ្នូរកូហ្វុននៅតំបន់ Mozu និង Furuichi

ប្រភព៖ https://www.bunka.go.jp






រូបលេខ៤៖រចនាសម្ព័ន្ធទូទៅនៃផ្នូរកូហ្វុន

ប្រភព៖ https://www.bunka.go.jp



រូបលេខ៥៖រូបគំនូរធ្វើឡើងវិញនៃផ្នូរកូហ្វុនដែលបង្ហាញពីបន្ទប់ ដែលដាក់មឈូស

ប្រភព៖ https://www.bunka.go.jp

អត្ថបទដោយ៖ អេង តុលា



រូបលេខ៦-៧៖វត្ថុសិល្បៈដែលបានរកឃើញនៅក្នុងផ្នូរ

ប្រភព៖ https://www.bunka.go.jp





រូបលេខ៨-៩៖រូបថតពីលើនៃតំបន់ដែលដែលមានផ្នូរ

ប្រភព៖ https://www.bunka.go.jp

អត្ថបទដោយ៖ អេង តុលា

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

# ឯកសារយោង

https://whc.unesco.org/en/list/1593
https://www.metmuseum.org/toah/hd/kofu/hd_kofu.htm

https://www.bunka.go.jp/seisaku/bunkazai/shokai/sekai_isan/ichiran/pdf/r1419077_06.pdf

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា